ក្រសួងអប់រំរដ្ឋ NSW



# ការធ្វើបច្ចុប្បន្នភាពនីតិវិធីចុះឈ្មោះចូលរៀន

## ព័ត៌មានសម្រាប់គ្រួសារ

## តើមានការផ្លាស់ប្តូរអ្វីនេះ?

ការផ្លាស់ប្តូរខាងក្រោមត្រូវបានធ្វើឡើងចំពោះនីតិវិធីឈ្មោះចូលរៀននៅមត្តេយ្យសាលា (Kindergarten) ដល់ថ្នាក់ទី 12 (Year 12) ហើយអនុវត្តចំពោះការចុះឈ្មោះចូលរៀននៅសាលារៀនរដ្ឋទាំងអស់ដែលចាប់ផ្តើមនៅត្រីមាសទី 1 ឆ្នាំ 2026។

### ការធ្វើបច្ចុប្បន្នភាពការចុះឈ្មោះពីក្រៅមូលដ្ឋាន

នៅឆ្នាំ 2025 យើងបានណែនាំលក្ខណៈវិនិច្ឆ័យដើម្បីផ្តល់អាទិភាពដល់ពាក្យសុំចុះឈ្មោះពីក្រៅមូលដ្ឋាន សម្រាប់សិស្សដែលមានតម្រូវការរៀនសូត្រ និងសុខុមាលភាពជាក់លាក់ បងប្អូនបង្កើតរបស់សិស្សដែលបានចុះឈ្មោះបច្ចុប្បន្ន និងកូនរបស់បុគ្គលិកសាលា។

នៅឆ្នាំ 2026 ការចុះឈ្មោះពីក្រៅមូលដ្ឋានក៏នឹងត្រូវបានផ្តល់អាទិភាពផងដែរសម្រាប់៖

- សិស្សជនជាតិដើម Aboriginal និង/ឬអ្នកកោះ Torres Strait ដើម្បីទទួលស្គាល់ទំនាក់ទំនងវប្បធម៌ គ្រួសារ និងទំនាក់ទំនងសាច់ញាតិ (kinship connections)។
- សិស្ស Kindergarten ដែលនឹងចូលរៀន ដែលបានចូលរៀននៅសាលាត្រៀមរដ្ឋមានទីតាំងរួមគ្នាជាមួយសាលារៀនរដ្ឋក្នុងរដ្ឋ NSW។

### ភាពបត់បែនកាន់តែច្រើនសម្រាប់កូនរបស់សមាជិកកងកម្លាំងការពារ

នីតិវិធីចុះឈ្មោះកំពុងត្រូវបានធ្វើបច្ចុប្បន្នភាព ដើម្បីធានាបាននូវភាពបត់បែនកាន់តែច្រើននៃតម្រូវការចុះឈ្មោះចូលរៀនសម្រាប់កូនរបស់សមាជិកកងកម្លាំងការពារក្នុងអំឡុងពេលផ្លាស់ប្តូរទីលំនៅ និងខណៈពេលកំពុងធានាបាននូវទីលំនៅ។

### ការទទួលស្គាល់ kinship របស់ជនជាតិដើម Aboriginal និង/ឬអ្នកកោះ Torres Strait

សាលារៀននឹងមានភាពបត់បែនកាន់តែច្រើនក្នុងការចុះឈ្មោះសិស្សជនជាតិដើម Aboriginal និង/ឬអ្នកកោះ Torres Strait រួមទាំង kinship connections សុវត្ថិភាពវប្បធម៌ សិទ្ធិទទួលបានការសិក្សាភាសាដើម Aboriginal និងទំនួលខុសត្រូវវប្បធម៌នានាដូចជា Sorry Business។

### និរន្តរភាពសម្រាប់សិស្សដែលងាយរងគ្រោះបំផុតរបស់យើង

ការណែនាំជាក់លាក់សម្រាប់សិស្សធានាឱ្យនៅក្រៅឃុំ និងសិស្សដែលកំពុងផ្លាស់ប្តូរពីសាលារៀននៅក្នុងមជ្ឈមណ្ឌលយុត្តិធម៌យុវជន និងការឃុំឃាំងក៏កំពុងត្រូវបានដាក់បញ្ចូល ហើយពាក្យសុំចុះឈ្មោះពីក្នុងមូលដ្ឋានសម្រាប់សិស្សក្នុងប្រភេទនេះឥឡូវនេះនឹងត្រូវដំណើរការក្នុងរយៈពេល 2 ថ្ងៃសិក្សា។



NSW GOVERNMENT

## សំណួរដែលគេសួរញឹកញាប់

### តើការផ្លាស់ប្តូរទាំងនេះអនុវត្តចំពោះកូនរបស់ខ្ញុំដែរឬទេ?

ការផ្លាស់ប្តូរឆ្នាំ 2026 ចំពោះនីតិវិធីចុះឈ្មោះនៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW ទាក់ទិននឹងអ្នក ប្រសិនបើ៖

- កូនរបស់អ្នកគឺជាជនជាតិដើម Aboriginal និង/ឬអ្នកកោះ Torres Strait ដែលមានការពិចារណាលើ kinship ភាសា ឬវប្បធម៌
- កូនរបស់អ្នកបានស្ថិតនៅក្រោមការថែទាំបណ្តោះអាសន្ននៅក្រៅក្រុមគ្រួសារ ការធានាឱ្យនៅក្រៅឃុំ ឬកំពុងផ្លាស់ប្តូរពីសាលារៀននៅក្នុងមជ្ឈមណ្ឌលយុត្តិធម៌យុវជន ឬការឃុំឃាំង
- ឪពុក ឬម្តាយម្នាក់របស់កូនអ្នកបានបម្រើការ ឬកំពុងបម្រើការក្នុងកងកម្លាំងការពារ ហើយអាចរងផលប៉ះពាល់ដោយតម្រូវការផ្លាស់ប្តូរទីលំនៅដែលបណ្តាលមកពីការអនុវត្តការងារសម្រាប់កងកម្លាំងការពារអូស្ត្រាលី។

### តើគ្រប់សាលារៀនទាំងអស់នឹងត្រូវបានតម្រូវឱ្យអនុវត្តការផ្លាស់ប្តូរទាំងនេះដែរឬទេ?

អាស្រ័យលើលទ្ធភាពដែលមានទីកន្លែងចុះឈ្មោះរបស់សាលារៀន សាលានានាត្រូវបានតម្រូវឱ្យអនុវត្តការផ្លាស់ប្តូរសម្រាប់ការចុះឈ្មោះពីក្រៅមូលដ្ឋានសម្រាប់សិស្សដែលចុះឈ្មោះសម្រាប់ត្រីមាសទី 1 ឆ្នាំ 2026។

ការផ្លាស់ប្តូរនីតិវិធីចុះឈ្មោះសម្រាប់សិស្សក្រៅមូលដ្ឋាន នឹងមិនប៉ះពាល់ដល់តម្រូវការសិទ្ធិទទួលបានសម្រាប់សាលាឯកទេស ឬកម្មវិធីឯកទេសដូចជា វិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យពេញលេញ សាលារៀនសម្រាប់គោលបំណងជាក់លាក់ (schools for specific purposes (SSPs)) សាលាអប់រំពីចម្ងាយ និងសាលារៀនដែលមានថ្នាក់ ឬកម្មវិធីមានលក្ខខណ្ឌតម្រូវជាក់លាក់ (ឧទាហរណ៍ ថ្នាក់សិស្សមានទេពកោសល្យ កីឡាឯកទេស និង/ឬសមត្ថភាពលើការច្នៃប្រឌិត ឬសិល្បៈសម្តែង)។ សាលារៀនទាំងនេះអាចមាននីតិវិធី លក្ខណៈវិនិច្ឆ័យសិទ្ធិទទួលបាន និងការវាយតម្លៃរបស់ខ្លួនផ្ទាល់ ហើយនឹងបន្តអនុវត្តដំណើរការចុះឈ្មោះបច្ចុប្បន្នរបស់ពួកគេ។

សាលារៀនសម្រាប់សិស្សភេទតែមួយត្រូវតែអនុវត្តការផ្លាស់ប្តូរទាំងនេះ ដរាបណាកុមារដែលកំពុងចុះឈ្មោះបំពេញតាមលក្ខខណ្ឌតម្រូវលើសិទ្ធិទទួលបានរបស់សាលាសម្រាប់ភេទនោះ។ សូមទាក់ទងសាលារៀនដែលពាក់ព័ន្ធ ដើម្បីសាកសួរពីរបៀបដែលការផ្លាស់ប្តូរទាំងនេះអនុវត្ត។

### តើពាក្យស្នើសុំរបស់ខ្ញុំសម្រាប់ការចុះឈ្មោះពីក្រៅមូលដ្ឋាននឹងត្រូវបានទទួលយកដោយស្វ័យប្រវត្តិទេ ប្រសិនបើកូនរបស់ខ្ញុំបំពេញតាមលក្ខណៈវិនិច្ឆ័យដែលបានធ្វើបច្ចុប្បន្នភាព?

ការផ្លាស់ប្តូរទាំងនេះមិនធានាការចុះឈ្មោះកូនរបស់អ្នកនៅសាលារៀនរដ្ឋក្រៅមូលដ្ឋានទេ។ សាលារៀនដែលមានទីកន្លែងសម្រាប់ការចុះឈ្មោះក្នុងមូលដ្ឋាន និងពីក្រៅមូលដ្ឋាន នឹងពិចារណាលើពាក្យសុំរបស់អ្នក។ សាលារៀនដែលមានទីកន្លែងចុះឈ្មោះពីក្រៅមូលដ្ឋាន នឹងផ្តល់អាទិភាពដល់ការចុះឈ្មោះពីក្រៅមូលដ្ឋានសម្រាប់៖

- សិស្សដែលមានតម្រូវការរៀនសូត្រ និងសុខុមាលភាពដែលទាមទារការកែតម្រូវសមហេតុផល និង/ឬការគាំទ្រផ្នែកអប់រំបន្ថែម រួមទាំង
  - សិស្សជនជាតិដើម Aboriginal និង/ឬអ្នកកោះ Torres Strait ដែលមានការពិចារណាលើវប្បធម៌ និង/ឬទំនាក់ទំនងគ្រួសារ និង kinship connections ហើយនិងទំនាក់ទំនងនានា
  - ពិការភាព
  - អាយុអភិវឌ្ឍន៍
  - ការប៉ះទង្គិចផ្លូវចិត្ត
  - ការព្រួយបារម្ភអំពីការការពារកុមារ
  - តម្រូវការផ្នែកវេជ្ជសាស្ត្រ និងបុគ្គល និងកាលៈទេសៈនានា
- បងប្អូនបង្កើតរបស់សិស្សដែលកំពុងចូលរៀននៅសាលារៀននោះ ដែលមានបងប្អូនបង្កើតរបស់សិស្សនៅក្នុងអង្គភាពគាំទ្រដែលបានផ្តល់អាទិភាព
- សិស្ស Kindergarten ដែលនឹងចូលរៀន ដែលបានចូលរៀននៅសាលាត្រៀមរដ្ឋមានទីតាំងរួមគ្នាជាមួយសាលារៀននោះ។

សូមទាក់ទងសាលារៀនដែលពាក់ព័ន្ធសម្រាប់ព័ត៌មានបន្ថែម។

### តើនេះមានន័យថា មានតែសិស្សដែលបំពេញតាមលក្ខណៈវិនិច្ឆ័យអាទិភាពសម្រាប់ការចុះឈ្មោះពីក្រៅមូលដ្ឋានទេឬ ដែលនឹងត្រូវទទួលយកចាប់ពីពេលនេះតទៅ?

ទេ ឪពុកម្តាយត្រូវបានស្វាគមន៍ក្នុងការដាក់ពាក្យសុំចុះឈ្មោះកូនរបស់ពួកគេនៅសាលារៀនរដ្ឋណាមួយ ប្រសិនបើកូននោះមានសិទ្ធិចូលរៀននៅសាលានោះ ហើយសាលាអាចផ្តល់ទីកន្លែងតាមលទ្ធភាពដែលមានសម្រាប់ការចុះឈ្មោះ។ សាលារៀនទាំងអស់ដែលមានទីកន្លែងសម្រាប់ការចុះឈ្មោះពីក្រៅមូលដ្ឋានដែលមានកំណត់ ត្រូវតែផ្តល់អាទិភាព និងពិចារណាលើពាក្យសុំទល់នឹងលក្ខណៈវិនិច្ឆ័យនៃការចុះឈ្មោះពីក្រៅមូលដ្ឋានដែលបានធ្វើបច្ចុប្បន្នភាព។

### ពាក្យសុំចុះឈ្មោះពីក្រៅមូលដ្ឋានពីមុនរបស់ខ្ញុំត្រូវបានបដិសេធ ប៉ុន្តែកូនរបស់ខ្ញុំឥឡូវនេះបំពេញតាមលក្ខណៈវិនិច្ឆ័យដែលបានធ្វើបច្ចុប្បន្នភាព។ តើខ្ញុំអាចដាក់ពាក្យសុំម្តងទៀតបានដែរឬទេ?

បាន។ ប្រសិនបើអ្នកបានដាក់ពាក្យសុំសម្រាប់កូនរបស់អ្នកទៅរៀននៅសាលារៀនក្រៅមូលដ្ឋានក្នុងឆ្នាំ 2026 ហើយពាក្យសុំនោះត្រូវបានបដិសេធ អ្នកអាចដាក់ពាក្យសុំម្តងទៀតបាន ប្រសិនបើកូនរបស់អ្នកបំពេញតាមលក្ខណៈវិនិច្ឆ័យនៃការចុះឈ្មោះពីក្រៅមូលដ្ឋានដែលបានធ្វើបច្ចុប្បន្នភាព។ សូមអនុវត្តតាមជំហានដែលបានរៀបរាប់នៅផ្នែកខាងក្រោម "តើខ្ញុំត្រូវផ្លាស់ប្តូរទីកន្លែងដែលខ្ញុំបានចុះឈ្មោះកូនរបស់ខ្ញុំដោយរបៀបណា?"។

### ខ្ញុំបានដាក់ស្នើការបញ្ចេញចំណាប់អារម្មណ៍ (Expression of Interest (EOI)) សម្រាប់ការធ្វើអន្តរកាល Year 6 ទៅថ្នាក់ទី 7។ តើខ្ញុំអាចផ្លាស់ប្តូរកន្លែងដែលខ្ញុំបានចុះឈ្មោះកូនរបស់ខ្ញុំបានដែរឬទេ?

បាន។ ប្រសិនបើកូនរបស់អ្នកបំពេញតាមលក្ខណៈវិនិច្ឆ័យនៃការចុះឈ្មោះពីក្រៅមូលដ្ឋានដែលបានធ្វើបច្ចុប្បន្នភាព អ្នកអាចដាក់ពាក្យសុំថ្មីទៅសាលារៀនក្រៅមូលដ្ឋានដែលអ្នកពេញចិត្ត ទោះបីជាអ្នកបានដាក់ស្នើ EOI រួចហើយសម្រាប់ការធ្វើអន្តរកាលពី Year 6 ទៅថ្នាក់ទី 7 ក៏ដោយ។ សូមអនុវត្តតាមជំហានដែលបានរៀបរាប់នៅផ្នែកខាងក្រោម "តើខ្ញុំត្រូវផ្លាស់ប្តូរទីកន្លែងដែលខ្ញុំបានចុះឈ្មោះកូនរបស់ខ្ញុំដោយរបៀបណា?"។

### តើខ្ញុំផ្លាស់ប្តូរទីកន្លែងដែលខ្ញុំបានចុះឈ្មោះកូនរបស់ខ្ញុំដោយរបៀបណា?

ឪពុកម្តាយ ឬអ្នកថែទាំដែលចង់ចុះឈ្មោះកូនរបស់ពួកគេនៅ សាលារៀនក្រៅមូលដ្ឋានត្រូវអនុវត្តតាមជំហានទាំងនេះដើម្បីផ្លាស់ប្តូរការចុះឈ្មោះរបស់ពួកគេ៖

#### ពាក្យសុំចុះឈ្មោះតាមអនឡាញ

1. ចូលទៅកាន់គេហទំព័រសាលារៀនរដ្ឋដែលអ្នកចង់ដាក់ពាក្យសុំចុះឈ្មោះ បន្ទាប់មកចុចលើការចុះឈ្មោះ (enrolment ) នៅក្នុងជម្រើសម៉ឺនុយ។
2. នៅលើទំព័របណ្តាញការចុះឈ្មោះ នៅក្រោមចំណងជើង របៀបចុះឈ្មោះ (how to enrol) ចុចលើតំណភ្ជាប់ទៅកាន់ពាក្យសុំចុះឈ្មោះតាមអនឡាញ (online enrolment application)។
3. បន្ទាប់ពីអ្នកបានដាក់ពាក្យសុំចុះឈ្មោះរបស់អ្នកហើយ សាលារៀនអាចផ្តល់ទីកន្លែងឱ្យអ្នក ដែលអ្នកនឹងត្រូវទទួលយកក្នុងរយៈពេល 14 ថ្ងៃ។
4. ប្រសិនបើពាក្យសុំរបស់អ្នកត្រូវបានទទួលយក សូមទាក់ទងសាលារៀនដែលកូនរបស់អ្នកបានចុះឈ្មោះពីមុន ដើម្បីដកចេញការចុះឈ្មោះនោះ។

### ពាក្យសុំជាទម្រង់បែបបទក្រដាសស្នាម

1. ទាក់ទងសាលារៀនរដ្ឋក្រៅមូលដ្ឋាន ដើម្បីរកមើលថាតើពួកគេអាចផ្តល់ទីកន្លែងរៀនសម្រាប់កូនរបស់អ្នកដែរឬទេ។
2. ប្រសិនបើសាលាអាចផ្តល់ទីកន្លែងរៀនសម្រាប់កូនរបស់អ្នក សូមបំពេញពាក្យសុំជាទម្រង់បែបបទក្រដាសស្នាមមួយ ដែលសាលាអាចផ្តល់ជូន។
3. បន្ទាប់ពីអ្នកបានដាក់ពាក្យសុំចុះឈ្មោះរបស់អ្នកហើយ សាលារៀនអាចផ្តល់ទីកន្លែងឱ្យអ្នក ដែលអ្នកនឹងត្រូវទទួលយកក្នុងរយៈពេល 14 ថ្ងៃ។
4. ប្រសិនបើពាក្យសុំរបស់អ្នកត្រូវបានទទួលយក សូមទាក់ទងសាលារៀនដែលកូនរបស់អ្នកបានចុះឈ្មោះពីមុន ដើម្បីដកចេញការចុះឈ្មោះនោះ។

## ចុះបើខ្ញុំមិនមានអាសយដ្ឋានអចិន្ត្រៃយ៍ ឬឯកសារបញ្ជាក់អត្តសញ្ញាណដែលតម្រូវ?

មានកាលៈទេសៈនានាដែលសិស្សអាចចុះឈ្មោះដោយគ្មានភស្តុតាងអាសយដ្ឋាន។ កាលៈទេសៈទាំងនេះរួមមាន ប៉ុន្តែមិនត្រូវបានកំណត់ចំពោះ ការពិចារណាអំពីវប្បធម៌ កូនរបស់សមាជិកកងកម្លាំងការពារ និងកុមារ ឬមនុស្សវ័យក្មេងស្ថិតនៅក្រោមការថែទាំបណ្តោះអាសន្ននៅក្រៅក្រុមគ្រួសារ ការធានាឱ្យនៅក្រៅឃុំ ឬកំពុងផ្លាស់ប្តូរពីសាលារៀននៅក្នុងមជ្ឈមណ្ឌលយុត្តិធម៌យុវជន និងការឃុំឃាំង។ សូមទាក់ទងសាលារៀនដែលពាក់ព័ន្ធសម្រាប់ព័ត៌មានបន្ថែម ប្រសិនបើអ្នកយល់ឃើញថានេះអាចអនុវត្តចំពោះស្ថានភាពរបស់អ្នក។

## តើការផ្លាស់ប្តូរគោលនយោបាយ និងនីតិវិធីនៃការចុះឈ្មោះឆ្នាំ 2025 នៅតែអនុវត្តឬ?

នៅតែអនុវត្ត។ ការផ្លាស់ប្តូរដែលបានណែនាំនៅឆ្នាំ 2025 នឹងបន្តអនុវត្តសម្រាប់ការចុះឈ្មោះឆ្នាំ 2026។ ទាំងនេះរួមមាន៖

- សិស្សទាំងអស់ដែលកាន់ទិដ្ឋាការស្នាក់នៅបណ្តោះអាសន្ន អាចចុះឈ្មោះនៅសាលារៀនរដ្ឋក្នុងមូលដ្ឋានរបស់ពួកគេ ដោយផ្អែកលើអាសយដ្ឋានស្នាក់នៅរបស់ពួកគេ។
- បងប្អូនបង្កើតរបស់សិស្សដែលបានចុះឈ្មោះបច្ចុប្បន្ននៅសាលារៀនរដ្ឋ ត្រូវបានផ្តល់អាទិភាពសម្រាប់ការចុះឈ្មោះពីក្រៅមូលដ្ឋាន ដោយផ្តល់អាទិភាពដល់បងប្អូនបង្កើតរបស់សិស្សរៀននៅក្នុងថ្នាក់គាំទ្រនៅក្នុងសាលាជាមួយសិស្សទូទៅដែលមានសិទ្ធិទទួល។
- កូនរបស់បុគ្គលិកសាលាអាចត្រូវបានពិចារណាសម្រាប់ការចុះឈ្មោះពីក្រៅមូលដ្ឋាននៅសាលារៀនរដ្ឋ។

សម្រាប់ព័ត៌មានបន្ថែមអំពីការផ្លាស់ប្តូរទាំងនេះ ឬដើម្បីពិនិត្យមើលថាតើវាអនុវត្តចំពោះកូនរបស់អ្នកឬអត់ សូមទាក់ទងសាលារៀនដែលពាក់ព័ន្ធ។

## តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមនៅឯណា?

**សម្រាប់ការសាកសួរអំពីការចុះឈ្មោះ សូមនិយាយទៅកាន់សាលារៀនដែលអ្នកនិយមចូលចិត្ត។ ស្វែងរកព័ត៌មានលម្អិតទំនាក់ទំនងសាលារបស់អ្នកនៅ៖**
education.nsw.gov.au/find-a-public-school

**សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបចុះឈ្មោះនៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW៖**
education.nsw.gov.au/enrolment

**សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបចុះឈ្មោះនៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW ក្នុងឋានៈអ្នកស្នាក់នៅបណ្តោះអាសន្ន៖**
https://www.deinternational.nsw.edu.au/

**សម្រាប់ការសាកសួរអំពីការចុះឈ្មោះទូទៅ សូមទាក់ទងការិយាល័យកណ្តាលរបស់ក្រសួងអប់រំ៖** 1300 679 332

**សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ**

ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ដើម្បីជួយអ្នកក្នុងការទាក់ទងមកសាលារៀន ឬក្រសួងអប់រំ សូមទូរសព្ទទៅសេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទលេខ 13 14 50 ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក។ ប្រាប់ការីទូរសព្ទនូវលេខទូរសព្ទដែលអ្នកចង់ហៅ ហើយការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់ម្នាក់តាមទូរសព្ទ ដើម្បីជួយក្នុងការសន្ទនារបស់អ្នក។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។


NSW GOVERNMENT